# ញឹក ជូឡុង
# (១៩០៨ - ១៩៩៦)

លោក ញឹក ជូឡុង កើតនៅថ្ងៃទី ២៣ សីហា ១៩០៨ នៅក្រុងភ្នំពេញ ពីគ្រួសារមន្ត្រីជិតស្និទ្ធព្រះរាជវាំង ។ លោកជាឪពុក លោកស្រី ជូឡុង សូម្ម៉ា ភរិយា លោក សម រង្ស៊ី ប្រធាន គណបក្សប្រឆាំង នៅកម្ពុជា ។

លោក ញឹក ជូឡុង បានសិក្សានៅ អនុវិទ្យាល័យ ស៊ីសុវត្ថិ នៅភ្នំពេញ និង វិទ្យាល័យ ***CHASSELOUP LAUBAT*** នៅព្រៃនគរ ។ នៅវិទ្យាល័យនេះ លោកបានទទួល សញ្ញាប័ត្រមធ្យមសិក្សា ផ្នែកទស្សនវិជ្ជា ។

លោក ញឹក ជូឡុង បានចូលបំរើការងាររដ្ឋបាល នៅឆ្នាំ ១៩៣២ ដែលគាត់បានទទួលបុណ្យសក្តិឡើងជាលំដាប់ថ្នាក់ ៖ ឆ្នាំ ១៩៣៧ ជា អភិបាល ខេត្តពោធិ៍សាត់, ឆ្នាំ ១៩៣៩-៤៤ ជា អភិបាល ខេត្តកំពង់ចាម ។ នៅថ្ងៃ ៩ មីនា ១៩៤៥ មានការចាប់ឃុំខ្លួនបារាំង នៅកម្ពុជា ដោយកងកម្លាំងជប៉ុន លោក ញឹក ជូឡុង បានត្រូវតែងតាំងជា អភិបាល ក្រុង-ភ្នំពេញ ។ ពីថ្ងៃ ១៤ សីហា ដល់ថ្ងៃ ១៦ តុលា ១៩៤៥ (៣ ខែ) គាត់ជា រដ្ឋមន្ត្រីអប់រំជាតិ នៃ រដ្ឋាភិបាល លោក សឺង ង៉ុកថាញ់ ។ ពេលដែលបារាំងវិលត្រឡប់មកវិញ ពីថ្ងៃ ១៧ តុលា ១៩៤៥ ដល់ថ្ងៃ ១៤ ធ្នូ ១៩៤៦ គាត់ជា រដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ នៃ រដ្ឋាភិបាល ដឹកនាំដោយ ស៊ីសុវត្ថិ មុនីរ៉េត ។ នៅពេលនោះ គាត់ជាមន្ត្រីហែហម ព្រះមហាក្សត្រ នរោត្តម សីហនុ មកស្រុកបារាំង ពីខែ មេសា ដល់ មិថុនា ១៩៤៦ ។ នៅថ្ងៃទី ៧ ធ្នូ ១៩៤៦ គាត់បានត្រូវតែងតាំងជា សមាជិក ប្រតិភូត្រួតពិនិត្យពួកថៃ ឲ្យចាកចេញពី ខេត្តបាត់ដំបង ដែលពួកវាបានមកកាន់កាប់ខេត្តនេះ តាំងពីឆ្នាំ ១៩៤១ មក ។ នៅឆ្នាំ ១៩៤៧ គាត់បានបង្កើត គណៈបក្ស "ខេមរៈប៉ុណ្ណាការ" ដើម្បីចូលរួមបោះឆ្នោត តែគ្មានបានទទួលអាសនៈនៅសភាទេ ។ នៅខែមេសា ១៩៤៨ គាត់ជា ប្រតិភូរបស់រដ្ឋាភិបាលកម្ពុជា អមឧត្តម-ស្នងការបារាំង នៅឥណ្ឌូចិន និង នៅខែសីហា ឆ្នាំដដែល គាត់ជា ប្រតិភូកម្ពុជា នៅឧត្តម-ក្រុមប្រឹក្សាសហភាពបារាំង នៅប៉ារីស ។ នៅខែកញ្ញា គាត់ជា សមាជិក គណៈប្រតិភូបារាំង នៅ អ.ស.ប. មានឋានៈជា ទីប្រឹក្សា ។ នៅថ្ងៃទី ២២ វិច្ឆិកា ១៩៤៩ គាត់បានទទួលឋានន្តរសក្តិ ជាវរសេនីយឯក និង ជានាយកអគ្គបញ្ជាការ កងទ័ពខេមរភូមិន្ទ ។ នៅឆ្នាំ ១៩៥០ លោកបានត្រូវតែងតាំងជា អភិបាលខេត្តបាត់ដំបង ដែលមានឋានៈស្មើ រដ្ឋមន្ត្រី ។ នៅថ្ងៃទី ១ មករា ១៩៥១ គាត់បានវិលមកកាន់ រដ្ឋាភិបាល វិញ មានឋានៈជា រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រហូតដល់ថ្ងៃទី ១៤ ឧសភា ១៩៥១ ។ ថ្ងៃទី ៩ ខែកញ្ញា ១៩៥១ ដោយមានការចូលរួមពី លោក លន់ នល់ គណបក្ស ខេមរៈប៉ុណ្ណាការ បានចូលរួមបោះឆ្នោតសភានីតិបញ្ញត្តិ បានទទួល ២ អាសនៈ ក្នុងសភាមានអាសនៈទាំងអស់ ៧៨ ។ នៅឆ្នាំ ១៩៥៣ ស្តេច សីហនុ បានចាកចេញពីភ្នំពេញ ដើម្បីធ្វើ រាជបូជនីយកិច្ចទាមទារឯករាជ្យ លោក ញឹក ជូឡុង ទទួលភារៈដឹកនាំ ក្រសួងភូមិន្ទពត៌មាន តាំងនៅបាត់ដំបង ។ នៅចុងឆ្នាំ ១៩៥៣ ពេលដែលកម្ពុជាបានទទួលឯករាជ្យបរិបូណ៌ពីបារាំង លោក ញឹក ជូឡុង បានត្រូវតែងតាំងជាថ្មី អភិបាលក្រុងភ្នំពេញ ។ នៅថ្ងៃទី ៧ មេសា ១៩៥៤ គាត់បានត្រូវតែង-តាំងជា ទេសរដ្ឋមន្ត្រី ទទួលបន្ទុក ក្រសួងការបរទេស និង សន្និសីទ (ហ្សឺណែវ) បន្ទាប់មកនៅថ្ងៃទី ១៨ មេសា ១៩៥៤ គាត់មានភារៈមើល ក្រសួងការពារជាតិ រហូតដល់ថ្ងៃទី ៣១ កក្កដា ១៩៥៤ ។ នៅពេលនោះ គាត់បានទទួលឋានន្តរសក្តិជា ឧត្តមសេនីយខ្មែរទី ១ (លោក លន់ នល់ ជាឧត្តមសេនីយទី ២ ឆ្នាំ ១៩៥៥) ដឹកនាំ ប្រតិភូខ្មែរ ផ្នែកយោធា មកចូលរួមសន្និសីទហ្សឺណែវ ។ ក្នុងប្រតិភូយោធា មាន ៖ ញឹក ជូឡុង, នរោត្តម ចន្ទរង្សី, ដាប ឈួន, ពុត ឆាយ ។ ប្រតិភូខ្មែរ ផ្នែកស៊ីវិល តំណាង មហាក្សត្រ សីហនុ មាន៖ ទេព ផន, សម សារី, ស៊ឹន សាន, ប៉ុក ធឿន, កុច សន, ហេងលី គិមហេង ។ បន្ទាប់ពី សន្និ-សិទ្ធហ្សឺណែវ ចប់រួចហើយ ដែលធានាឲ្យកម្ពុជា គ្មានបែងចែកទឹកដី លោក ញឹក ជូឡុង បានប្តូរមកជាអាជីព អង្គទូត វិញ ៖ ពីឆ្នាំ ១៩៥៥ ដល់ ១៩៥៧ លោកជា អគ្គរាជទូតខ្មែរនៅ ជប៉ុន, សហភាពសូវៀត, ប៉ូឡូញ និង ឆេកូស្លូវ៉ាគី ។ ពីឆ្នាំ ១៩៥៨ ដល់ ១៩៦២ គាត់បានវិលត្រឡប់ចូលរដ្ឋាភិបាលវិញ ។ ពីថ្ងៃទី ១៣ កុម្ភៈ ១៩៦២ ដល់ ថ្ងៃ ៦ សីហា ១៩៦២ គាត់ជា នាយករដ្ឋមន្ត្រី ។

នៅឆ្នាំ ១៩៦៥ គាត់បានថតកុន នៃ ខ្សែភាពយន្តខ្នាតវែង "អប្សរា" របស់ សម្តេច សីហនុ ដោយលោកបានដើរតួ ឧត្តមសេនីយ ឫទ្ធី, ព្រះអង្គម្ចាស់ បុប្ផាទេវី ជា នាង គន្ធបុប្ផា ។

នៅឆ្នាំ ១៩៦៩ គាត់បានដកខ្លួនមករស់នៅស្រុកបារាំង ទើបតែមកដល់ ទសវត្ស ៨០ ទើបលេចឈ្មោះជាថ្មី ។ ចលនាតស៊ូ ហ៊្វុនស៊ិនប៉ិក ប្រឆាំងទៅរបបតែងតាំងដោយយួន បានបង្កើតឡើង ដោយ សម្តេច សីហនុ ជាប្រធាន លោក ញឹក ជូឡុង ជាអនុប្រធាន ។ ពីឆ្នាំ ១៩៨៩ ដល់ ១៩៩២ គាត់ជា ប្រធាន ហ៊្វុនស៊ិនប៉ិក ។ លោក ញឹក ជូឡុង បានទទួលអនិច្ចកម្ម នៅថ្ងៃទី ៩ មិថុនា ១៩៩៦ ក្នុងជន្មាយុ ៨៨ ឆ្នាំ នៅមន្ទីរពេទ្យ ក្រុងហុងកុង ៕



Nhiek Tioulong, Dap Chhuon, Pat Chhay à la Conférence de Genève en 1954.

Film APSARA-1966
de Norodom Sihanouk

Personnages :
S.A.R. Princesse
BOPHA DEVI
---> Neang Kantha Devi
S.E. NHIEK TIOULONG
---> Général Rithi








*Le prince Sihanouk et le général Nhiek Tioulong présentent une carte détaillée des implantations des forces nord-vietnamiennes et Vietcong (28/03/1969)*




លោក ញឹក ជូឡុង ដឹកនាំប្រតិភូយោធាខ្មែរមាន៖ ញឹក ជូឡុង, នរោត្តម ចន្ទ រឿ, ដាប ឈួន, ពុត ឆាយ មកចូលរួមសន្និសីទហ្សឺណែវឆ្នាំ១៩៥៤



# Nhiek Tioulong (1908-1996)

**Nhiek Tioulong** (Phnom Penh, 23 août 1908 – Hong Kong 9 juin 1996) était un homme politique cambodgien.
Officier de l'armée cambodgienne, il fut aussi membre de nombreux gouvernements après l'indépendance du pays et notamment **Premier ministre en 1962.**
Proche de la droite cambodgienne, il a néanmoins gardé ses distances avec les dirigeants de la République khmère.
Il est aussi connu pour être le beau-père de Sam Rainsy, le principal opposant au régime actuel de Phnom Penh.

**Biographie**

Nhiek Tioulong est né à Phnom Penh, dans une famille de mandarins proches du palais. Il est le père de **Tioulong Saumura, elle-même épouse de Sam Rainsy.**
Après des études primaires au collège Sisowath à Phnom Penh, il rejoint le lycée Chasseloup Laubat de Saigon où il passe avec succès un baccalauréat de philosophie.
- Il rentre en 1932 dans l'administration, où il gravit les échelons jusqu'à devenir, en 1937, gouverneur de la province de Pothisat, puis, de 1939 à 1944, de celle de Kompong Cham.
- Le 9 mars 1945, à la faveur du coup de force japonais contre l'administration coloniale française, il est nommé gouverneur de la ville de Phnom Penh.
- Du 14 août au 16 octobre 1945, il est ministre de l'Éducation nationale dans un cabinet dirigé par Son Ngoc Thanh.
- Au retour des Français, il reste, du 17 octobre 1945 au 14 décembre 1946, au gouvernement en tant que ministre des Finances d'un cabinet présidé par Sisowath Monireth. Durant cette période, il fera partie des dignitaires qui accompagneront le roi Norodom Sihanouk en France, d'avril à juin 1946.
- Le 7 décembre 1946, il est chargé de superviser le départ des Thaïlandais de Battambang, qu'ils occupaient depuis cinq ans, et doit remettre en place l'administration khmère dans ce secteur.
- En 1947, il crée le « Kanapac Khemara Vothanaka » (parti de la rénovation khmère) proche de la droite et qui participe la même année aux élections législatives mais ne recueille aucun siège.
- En avril 1948, il devient délégué du gouvernement cambodgien auprès du haut commissaire français en Indochine, puis, en août de la même année, délégué du Cambodge au Haut Conseil de l'Union française à Paris. En septembre, il fait partie de la délégation française à l'ONU, en tant que conseiller.
- Le 22 novembre 1949, il est nommé colonel de l'armée royale khmère et chef d'État-major.
Il quitte ce poste rapidement et, dès fin décembre 1949, il retrouve son poste de délégué auprès du haut commissaire français, puis devient délégué du Cambodge à la commission d'application des accords franco-khmers.
- En mai 1950, il est nommé gouverneur de Battambang avec rang de ministre.
- Le 1er janvier 1951, il revient au gouvernement en tant que ministre des finances, poste qu'il conservera jusqu'au 14 mai 1951, date à laquelle il devient ministre d'État chargé de l'informa-

- Aux élections de 1951, le parti de la rénovation khmère, renforcé par Lon Nol, obtient 2 sièges.
- En juin 1953, alors que Norodom Sihanouk s'est exilé de Phnom Penh pour mener à bien sa croisade pour l'indépendance, Tioulong Nhiek dirige le service royal de l'information, installé à Battambang.
- À la fin décembre 1953, l'indépendance acquise, il est nommé à nouveau gouverneur de Phnom Penh et prend part aux négociations avec les Français concernant les derniers transferts de compétences entre l'administration coloniale et le gouvernement cambodgien.

Le 7 avril 1954, il est nommé ministre d'État chargé des Affaires étrangères et de la conférence (de Genève), puis, le 18 avril 1954, il est chargé de la défense nationale, et ce jusqu'au 31 juillet 1954. Il devient le premier général de l'Armée royale khmère (le second sera Lon Nol, en 1955) et sera le représentant militaire du Cambodge aux Accords de Genève.

En 1955, il entame une carrière d'ambassadeur, au Japon tout d'abord, puis, en 1957, en URSS, en Pologne et enfin en Tchécoslovaquie.

En 1958 il retourne au Cambodge et intègre plusieurs gouvernements :

- du 22 janvier au 29 avril 1958 : ministre d'État chargé de l'Intérieur, de la Sécurité nationale et de l'Information.
- du 30 avril au 10 juillet 1958 : vice-président du Conseil, ministre du Plan, de la Production, des Affaires économiques, des Travaux publics, des Télécommunications et du Tourisme.
- du 18 février au 13 juin 1959 : vice-président du Conseil (avec Son Sann), ministre de l'Intérieur, de la Justice, de l'Information, du Plan et de l'Assainissement général.
- du 14 juin 1959 au 19 avril 1960 : vice-président du Conseil, ministre de l'Éducation nationale, du Plan et du Tourisme.
- du 20 avril 1960 au 28 janvier 1961 : premier vice-président du Conseil, ministre du Plan, du Tourisme, de la Production, des Travaux publics et des Télécommunications.
- du 29 janvier 1961 au 12 février 1962 : ministre d'État chargé des affaires étrangères et du tourisme.
- du 13 février au 6 août 1962 : Président du Conseil.

En octobre 1962, il est nommé gouverneur de Kirirom.

Le 6 novembre 1962, il devient inspecteur des forces armées royales khmères et vice-président du Haut conseil du trône.

En 1965, il s'essayera au cinéma et sera l'acteur principal dans « Apsara », premier long métrage du prince Norodom Sihanouk.

En octobre 1966, il remplacera brièvement Lon Nol (devenu ministre) à la tête de l'armée.

En 1969, il se retire en France et reste dans l'ombre jusqu'au milieu des années 1980 où il devient vice-président du Front uni national pour un Cambodge indépendant, neutre, pacifique et coopératif (FUNCINPEC). Ce parti a été créé parNorodom Sihanouk pour combattre le nouveau régime mis en place à Phnom Penh par les troupes vietnamiennes.

Il dirigera même le FUNCINPEC de 1989 à 1992, à la place de Norodom Sihanouk.

Le 26 octobre 1993, il est nommé conseiller privé du roi.

Il meurt dans un hôpital de Hong Kong le 9 juin 1996.